# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦២

## ស្តីពី

## សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រសួងការបរទេស

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនាសមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រសួងការបរទេស
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៥



Downloaded from http://www.khmerlaws.com

# ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

ត្រូវបានបង្កើត សញ្ញាស័ក្តិ និងឯកសណ្ឋាន សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការការបរទេស ។

**មាត្រា២ :**

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សម្រាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

**មាត្រា៣ :**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រើសញ្ញាជាតិជាសញ្ញារបស់ក្រសួង ។

សញ្ញានេះ សំរាប់ដាក់នៅលើស័ក្តិស្មា ស័ក្តិកអាវ នៃមន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ មន្ត្រីក្រមការការបរទេស និងស័ក្តិខ្ទាស់លើអាវបុរស ឬលើក្រមាពានារបស់នារី ដែលជាមន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ។

## ជំពូកទី ២
## សញ្ញាស័ក្តិ

**មាត្រា ៤ :**

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការការបរទេស នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដូចតទៅ ÷

### ក._ ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

#### ១._ អំពីស័ក្តិស្មា

ស័ក្តិស្មាមានផ្ទៃកម្ញីពណ៌ខៀវចាស់ រចនាគុបតែងដោយក្បាច់គូរស្រូវពណ៌មាស និងក្បាច់សន្ធឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនេះមានសញ្ញាជាតិពណ៌មាស និងនៅពីលើសញ្ញាជាតិមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញក្នុងឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របីនេះមានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាស បីខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិវរមន្ត្រីការបរទេស និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ។



Downloaded from http://www.khmerlaws.com

ខ្នាតស័ក្តិស្មាត្រូវកំណត់ដូចខាងក្រោម ÷

- បាតក្រោម : ប្រវែង ៦ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើ : ប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោម : ប្រវែង ១៣ សង្ទីម៉ែត្រ

**២._ អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កួរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយមានសញ្ញាជាតិពណ៌មាសនៅពីខាងមុខ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញ និងមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខ បីខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិវរមន្ត្រីការបរទេស និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ។

ខ្នាតស័ក្តិចុងកអាវត្រូវកំណត់ដូចខាងក្រោម ÷

- មានរាងជាប្រលេឡូក្រាម
- បណ្តោយ : ប្រវែង ៩ សង្ទីម៉ែត្រ
- ទទឹង : ប្រវែង ៣.៨ សង្ទីម៉ែត្រ

**៣ ._ អំពីស័ក្តិចុងដៃអាវ**

ស័ក្តិចុងដៃអាវមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានក្បាច់កួរស្រូវពណ៌មាសមួយនៅខាងចុង ហើយក្បាច់កួរស្រូវមួយទៀតខ្វែងនឹងគល់ក្បាច់ភ្ញីទេស ។ បន្ទាប់មក មានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសនៅជាយផ្នែកខាងលើ និងផ្នែកសងខាង ។ ផ្ទៃខាងក្រៅ នៃក្បាច់ធ្មេញក្របីនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង បីខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិវរមន្ត្រីការបរទេស និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ។ នៅបាតក្រោមបង្អស់នៃសញ្ញាស័ក្តិចុងដៃអាវមានខ្សែពួរវេញពណ៌មាសមួយខ្សែ ។

ខ្នាតស័ក្តិចុងដៃអាវទាំងសងខាង ត្រូវកំណត់ដូចខាងក្រោម ÷

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយ : ប្រវែង ៣២ សង្ទីម៉ែត្រ
- ទទឹង : ប្រវែង ៩ សង្ទីម៉ែត្រ

សញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់មន្ត្រី ÷

- ឋានន្តរស័ក្តិឧត្តមមន្ត្រី មានគំរូនៅក្នុងឧបសម្ព័ន្ធទី ១
- ឋានន្តរស័ក្តិវរមន្ត្រី មានគំរូនៅក្នុងឧបសម្ព័ន្ធទី ២
- ឋានន្តរស័ក្តិអនុមន្ត្រី មានគំរូនៅក្នុងឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យនេះ ។



Downloaded from http://www.khmerlaws.com

ដោយឡែក ស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់នារី មានទំហំដូចខាងក្រោមនេះ ÷

- ចំពោះស័ក្តិស្មាអាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យតាមមាឌរបស់នារី
- ស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងស័ក្តិចុងដៃអាវរបស់បុរស អាស្រ័យតាមមាឌរបស់នារី
- ស័ក្តិកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យតាមកម្ពស់ករបស់នារី ។

**ឃ.- អំពីស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់**

សញ្ញាស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់មានរាងសាជី ដែលបាតក្រោមមានរាងពងក្រពើ និងកំពូលរាងជ្រលម កម្ពស់ ៦ សង្ទីម៉ែត្រ ទទឹង ៥ សង្ទីម៉ែត្រ ។ ផ្ទៃកខាងក្នុងមានសញ្ញាជាតិពណ៌មាស បន្ទាប់មកមានក្បាច់ផ្ចេញក្របីពណ៌មាសព័ទ្ធអមផង។ ផ្ទៃកខាងក្រៅមានខ្សែពួរវៀញព័ទ្ធអមពណ៌មាស បីខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិវរមន្ត្រីការបរទេស និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ។

ស័ក្តិខ្ទាស់លើអាវនេះ សំរាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ ស័ក្តិនេះក៏សម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណី។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពានា សម្រាប់មន្ត្រីក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់មានដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ។

**ខ.- មន្ត្រីក្រុមការការបរទេស**

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្រុមការការបរទេស មានសណ្ឋានរូបភាព និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរស័ក្តិ ដូចសញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិសម្រាប់មន្ត្រីក្រុមការការបរទេសមានពណ៌ប្រាក់។

សញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់មន្ត្រីដែលមាន ÷

- ឋានន្តរស័ក្តិនាយក្រុមការការបរទេស មានគំរូនៅក្នុងឧបសម្ព័ន្ធទី ៥
- ឋានន្តរស័ក្តិក្រុមការដើមខ្សែការបរទេស មានគំរូនៅក្នុងឧបសម្ព័ន្ធទី ៦
- ឋានន្តរស័ក្តិក្រុមការការបរទេស មានគំរូក្នុងឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣

## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា៥ :**

ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រុមការការបរទេសនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដូចខាងក្រោម ÷



Downloaded from http://www.khmerlaws.com

ក._ ឯកសណ្ឋានផ្លូវការ

១._ ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ ដៃវែង មានស័ក្តិនៅលើស្មា ចុងកអាវ ចុងដៃអាវ អត់មានផែកខ្នង
- អាវកុដនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរ ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមខាងក្រោមរាងមូល ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវមូល មានរូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ នៃមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការការបរទេស
- អាវកុដនេះមានឡេវរូបព្រះរាជសង្ហារ ចំនួន៧ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ នៃមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការការបរទេស
- ខោជើងវែង ពណ៌ទឹកប៊ិចក្រមៅ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

២._ ចំពោះស្ត្រី

- អាវជីបរាងពណ៌ស ក្រណាត់ដូចអាវរបស់បុរស កតាំង ដៃវែង ត្រឹមភ្នែកគោលដៃ អត់មានផែកខ្នង អត់មានហោប៉ៅ ដាក់ឡេវរូបព្រះរាជសង្ហារ ចំនួន៥ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ នៃមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការការបរទេស
- មានស័ក្តិនៅលើស្មា ចុងកអាវ ចុងដៃអាវ តាមឋានន្តរស័ក្តិ
- សំពត់ហូលលាតពណ៌ខៀវក្រមៅមានរងជើង ក្បាច់ហូលពណ៌សកម្ពស់ ១០សង្ទីម៉ែត្រ និងមានសម្រុងលើភ្នែកគោលនៃស្មងជើងប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកម្ពស់
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែងពណ៌ស សម្រាប់ពេលព្រឹក ឬពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។

ខ._ ឯកសណ្ឋានប្រពៃណីជាតិ

១._ ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ ដៃវែង មានស័ក្តិនៅលើស្មា ចុងកអាវ ចុងដៃអាវ អត់មានផែកខ្នង
- អាវកុដនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរ ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមខាងក្រោមរាងមូល ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះរាជសង្ហារពណ៌មាស
- អាវកុដនេះ មានឡេវរូបព្រះរាជសង្ហារ ចំនួន ៧ ពណ៌មាស



Downloaded from http://www.khmerlaws.com

- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ
- ស្បែកជើងឃ្លុប ពណ៌ខ្មៅ កខ្ចី មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

២._ ចំពោះស្ត្រី

- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវជីបរាងពណ៌ស មានកមូល ដៃវែង និងមានស័ក្តិនៅចុងដៃអាវ
- ពានាក្រមាតាមពណ៌សំពត់ ឬពានាក្រមាពណ៌ស៊ីន្ទួន តាមពិធីការកំណត់
- នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានស័ក្តិខ្ចាស់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសម្រាប់ពេលព្រឹក ឬពណ៌ខ្មៅសម្រាប់ពេលល្ងាច
- កាបូបយួរដៃពណ៌ស ឬពណ៌ខ្មៅ ស្របតាមការប្រើស្បែកជើងពណ៌ស ឬពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រីដែលស្លៀកផាមួងចងក្បិន មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្របការការបរទេស នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដូចខាងក្រោម ÷

- ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ
- ចំពោះឯកសណ្ឋានប្រពៃណីជាតិ សម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗ ត្រូវកំណត់ឱ្យប្រើប្រាស់សម្រាប់តែមន្ត្រីក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ដែលមានឋានន្តរស័ក្តិជាឧត្តមមន្ត្រីការបរទេស ។

## ជំពូកទី ៤
## ឯកសណ្ឋានសម្រាប់ស្លៀកពាក់ក្នុងពិធីថ្វាយ ឬជូនសារតាំង

**មាត្រា ៧ :**

- សម្រាប់បុរស អាវកុដពណ៌ស កត្រង់ ដៃវែង មានស័ក្តិនៅលើស្មា ចុងកអាវ ចុងដៃអាវ ស្លៀកសំពត់ផាមួងចងក្បិនពណ៌ព្រីងទុំ
- សម្រាប់ស្ត្រី អាវជីបរាងពណ៌ស ក្រណាត់ដូចអាវរបស់បុរស កតាំង មានស័ក្តិនៅលើស្មា ចុងកអាវ ចុងដៃអាវ ស្លៀកសំពត់ផាមួងចងក្បិនពណ៌ព្រីងទុំ ។

រូបគំនូរឯកសណ្ឋាននេះមានគំរូដូចក្នុងឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យនេះ ។



Downloaded from http://www.khmerlaws.com

## ជំពូកទី ៥
## របបកំណត់ឯកសណ្ឋាន និងសញ្ញាស័ក្តិ

**មាត្រា ៨ :**

មន្ត្រីការទូតម្នាក់ៗត្រូវបានផ្តល់ជូននូវឯកសណ្ឋានផ្លូវការ និងឯកសណ្ឋានប្រពៃណីជាតិ ព្រមទាំងសញ្ញាស័ក្តិ និងសម្ភារៈផ្សេងៗទៀត ដូចចែងក្នុងព្រះរាជក្រឹត្យនេះ សម្រាប់ប្រើប្រាស់រយៈពេល បីឆ្នាំម្តង ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០ :**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០៨០៥.៣៨៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ... ៣៦៧ ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោម ឌី តាន់**



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ..............................នស/រកត/០៨០៥/៣៦២
ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិឧត្តមមន្ត្រី ( ពណ៌មាស )



ស័ក្តិកអាវ



ស័ក្តិបានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ..............................នស/រកត/០៨០៥/៣៦៤
ចុះថ្ងៃទី.....០៤.......ខែ..សីហា.......ឆ្នាំ ២០០៥ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិវរមន្ត្រី ( ពណ៌មាស )



សំក្តិករអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ..............................នស/រកត/០៨០៥/៣៦៤
ចុះថ្ងៃទី......០៨......ខែ...សីហា....ឆ្នាំ...២០០៥...ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិអនុមន្ត្រី ( ពណ៌មាស )




សំក្តិកអាវ




សំក្តិបានស្មា




សំក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យលេខ................នស/រកត/០៨០៥/៣៦២
ចុះថ្ងៃទី.០៩...ខែ.សីហា..ឆ្នាំ.២០០៥...ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# ស័ក្តិខ្នាស់លើអាវសំរាប់មន្ត្រី
# នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ (ពណ៌មាស)



សំរាប់ឋានន្តរស័ក្តិឧត្តមមន្ត្រី



សំរាប់ឋានន្តរស័ក្តិវរមន្ត្រី



សំរាប់ឋានន្តរស័ក្តិអនុមន្ត្រី

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខ.........នស/រកត/០៨០៥/៧៦២

ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិនាយក្រមការ (ពណ៌ប្រាក់)



ស័ក្តិកអាវ



ស័ក្តិបានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ..............................នស/រកត/០៨០២/៣៦២
ចុះថ្ងៃទី.....០៨.......ខែ..សីហា.......ឆ្នាំ ២០០៥...ស្ដីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិក្រមការដើមខ្សែ ( ពណ៌ប្រាក់ )



ស័ក្តិកអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ..........................នស/រកត/០៩០៥/៣៦២

ចុះថ្ងៃទី....០៨.......ខែ..សីហា.......ឆ្នាំ..២០០៥......ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិក្រមការ ( ពណ៌ប្រាក់ )



ស័ក្តិករអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យលេខ................នស/រកត/០៧០៥/៣៦២
ចុះថ្ងៃទី.០៩...ខែ.សីហា...ឆ្នាំ.២០០៥...ស្ដីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស



រូបគំនូរឯកសណ្ឋានផ្លូវការ សំរាប់បុរស និងស្ត្រី

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៖ នៃព្រះរាជក្រឹត្យលេខ................នស/រកត/០៩០៥/៣៦២

ចុះថ្ងៃទី.០៩...ខែ.កញ្ញា...ឆ្នាំ.២០០៥....ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស



រូបគំនូរឯកសណ្ឋានប្រពៃណី សំរាប់បុរស និងស្ត្រី

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យលេខ................នស/រកត/០៧០៥/៣៦២
ចុះថ្ងៃទី.០៧..ខែ.សីហា...ឆ្នាំ.២០០៥....ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងមន្ត្រីក្រមការ ការបរទេស



រូបគំនូរឯកសណ្ឋាន សំរាប់ឯកអគ្គរាជទូតស្លៀកពាក់
ក្នុងពិធីថ្វាយ ឬជូនសារតាំង

Downloaded from http://www.khmerlaws.com